# សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ

THE CAMBODIAN INDEPENDENT TEACHERS' ASSOCIATION

អាស័យដ្ឋាន: ផ្ទះលេខ ១៣៥ EEo ផ្លូវលេខ ៣៦០ សង្កាត់ បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

Address: #135EEo, Street 360,Sangkat Boeung KengKang3, Khan Chamkamon, Phnom Penh, Kingdom of Cambodia.

Fax/Phone: (855-23) 21 75 44, H/P (855-12) 930 706/ E-mail: CITA@bigpond.com.kh


---

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០២

**សូមគោរពជូន**

**សម្តេច ហ៊ុន-សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

កម្មវត្ថុ: សំណើសុំតំឡើងប្រាក់បៀវត្សរ៍ចំនួន៤០០,០០០រៀល( សែសិបម៉ឺនរៀល) ក្នុងមួយខែសំរាប់គ្រូម្នាក់ៗ ។

យោង: - ការអនុម័តដោយកិច្ចប្រជុំអន្តររដ្ឋាភិបាលពិសេស ស្តីអំពីស្ថានភាពគ្រូបង្រៀន ធ្វើនៅទីក្រុងប៉ារីសនាថ្ងៃទី ០៥ តុលា ឆ្នាំ ១៩៦៦ ។

- ទំនិញនៅលើទីផ្សារមានតំលៃកាន់តែខ្ពស់ទៅៗ

-គ្រូបង្រៀនកាន់តែមានជីវភាពលំបាកទៅៗ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើខ្ញុំមានកិត្តិយស សូមជំរាបជូនសម្តេចមេត្តាជ្រាបថាៈទាំងគ្រូបង្រៀនដែលចូលនិវត្តន៏ទាំងគ្រូបង្រៀនដែលកំពុងបង្រៀនបច្ចុប្បន្នមានក្តីអស់សង្ឃឹមយ៉ាងខ្លាំង ដែលមិនធ្លាប់បានទទួលប្រាក់បៀវត្សរ៏ និង ជីវភាពរស់នៅបានសមរម្យម្តងណាឡើយ ហើយបានទទួលរងនូវការលំបាកគ្រប់យ៉ាងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដោយសារតែប្រាក់បៀវត្សរ៏មានកំរិតទាប ។ម្យ៉ាងទៀតការតំឡើងប្រាក់បៀវត្សរ៏រយៈពេលកន្លងមកក្នុងកំរិតទាបបំផុត បើធៀបទៅនិងតំលៃទំនិញលើទីផ្សារ នេះចាត់ទុកថាបៀវត្សរ៏របស់គ្រូបង្រៀន មិនត្រូវបានតំឡើងឡើយ ពីព្រោះប្រាក់ខែតំឡើងបន្តិចតំលៃទំនិញក៏ឡើងដែរ ។ការដែលខ្វះខាតជីវភាពបែបនេះហើយបានជំរុញអោយគ្រូបង្រៀនដាច់ចិត្តធ្វើអ្វីៗខុសនិងនិយាមគរុកោសល្យបណ្តាលអោយវិស័យអប់រំមានការធ្លាក់ចុះរៀងរាល់ឆ្នាំ ហើយថែមទាំងគ្មានគុណភាពទៀតផង ។ យ៉ាងណាមិញសារលិខិតរបស់សម្តេច ក្នុងឱកាសបើកបវេស្សនកាលឆ្នាំសិក្សា ២០០២-២០០៣ ដែលមានចំនុច៥ ក្នុងនោះមិនបានលើកឡើងអំពីប្រាក់បៀវត្សរ៏របស់លោកគ្រូ-អ្នកគ្រូឡើយ ។ នេះបង្ហាញអោយឃើញថា សម្តេចមិនបានយកចិត្តទុកដាក់អំពីជីវភាពខ្វះខាតរបស់គ្រូបង្រៀននោះទេ ។ សូម្បីតែនៅក្នុងអនុសាសន៏ពាក់ព័ន្ធនិងកំរិតស្ថានភាពគ្រូបង្រៀនត្រូវបានអនុម័តដោយកិច្ចប្រជុំអន្តររដ្ឋាភិបាលពិសេស ស្តីពីកំរិតស្ថានភាពគ្រូបង្រៀន ធ្វើនៅទីក្រុងប៉ារីស នាថ្ងៃទី ០៥ តុលា ឆ្នាំ ១៩៦៦ ដែលសំរេចដំណើរការតំឡើងប្រាក់បៀវត្សរ៏មូលដ្ឋាន ពីថ្នាក់អប្បបរិមាទៅអតិបរិមា មិនគួរអូសបន្លាយលើសពីថេរវេលា១០ឆ្នាំឡើយ ។ ចំណែកនៅកម្ពុជាវិញជាង២០ឆ្នាំហើយ ប្រមុខរាជរដ្ឋាភិបាល មិនត្រូវបានអនុវត្តដូចនេះឡើយ ហើយកន្លងមកសម្តេចបានលើកតែពីបញ្ហា

កាត់បន្ថយភាពក្រីក្រ ការពង្រឹងគុណភាពអប់រំ និង ការអភិវឌ្ឍធនធានមនុស្ស ប៉ុន្តែប្រាក់ខែមិនត្រូវបានតំលើងជូនគ្រូបង្រៀនឡើយ ។ សម្តេចគួរជ្រាបថា ដើម្បីកាត់បន្ថយភាពក្រីក្រ និង ពង្រឹងគុណភាពអប់រំនៅកម្ពុជានោះ ចាំបាច់សម្តេចត្រូវគិតពីស្ថានភាពរស់នៅរបស់គ្រូបង្រៀនជាមុនសិន ព្រោះគ្រឹះអប់រំដែលសំខាន់បំផុតនោះគឺមានតែគ្រូបង្រៀននេះទេ ។

ដូច្នេះដើម្បីអោយគ្រប់ក្រសួងស្ថាប័នទាំងអស់មានអភិបាលកិច្ចល្អ និង វិស័យអប់រំមានគុណភាពសម្តេចត្រូវលប់បំបាត់អំពើពុករលួយ ហើយតំឡើងបៀវត្សរ៍ជូនគ្រូបង្រៀន មន្ត្រីរាជការ ប៉ូលិស និង ទាហ៊ានអោយបានសមរម្យ នេះជាអាទិភាពទីមួយមុននឹងនិយាយដល់ការអភិវឌ្ឍន៍សង្គម ។ បើមិនដូច្នេះទេ ការអភិវឌ្ឍន៍សង្គម គ្មានប្រសិទ្ធិភាព និង គ្មានគុណភាព ហើយប្រទេសកម្ពុជាយើងមិនអាចងើបរួចពីភាពក្រីក្របានឡើយ ។

អាស្រ័យហេតុដូចបានគោរព និង ជំរាបជូនខាងលើនេះ សូមសម្តេចមេត្តាជួយដោះស្រាយតាមការស្នើសុំតំឡើងប្រាក់បៀវត្សរ៍ជូនលោកគ្រូ-អ្នកគ្រូតាមគតិបណ្ឌិតដោយក្តីអនុគ្រោះ ។

សូមសម្តេចមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ ។

ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ

Chhun

រ៉ុង ឈុន

<u>ចម្លងជូន:</u>

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិ
- ក្រសួងអប់រំ យុវជន និង កីឡា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ស្ថានទូតនានាប្រចាំនៅកម្ពុជា
- អង្គការនានាប្រចាំនៅកម្ពុជា
- សារព័ត៌មានជាតិ និង អន្តរជាតិ
- ឯកសារ-កាលប្បវត្ត